# ព្រឹត្តិបត្រប្រចាំត្រីមាសទី២

## ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប

ខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៥

## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ **ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)** នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយមានស្ថាបនិកចំនួន ៣រូប និងត្រូវបានក្រសួងមហាផ្ទៃសម្រេចអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីសមាគមតាមរយៈលិខិតលេខ ១០៧៧ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។

ដោយមានការរីចម្រើន ទំនុកចិត្ត និងការទទួលបាននូវការគាំទ្រពីអាជីវករ ក្រុមហ៊ុន សហគ្រាសប្រតិបត្តិករទឹកស្អាតនានា និងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា សមាគមបានសម្រេចបញ្ចូនសមាជិកបន្ថែមមានទាំងរូបវន្តបុគ្គល និងនិតិបុគ្គលនៅក្នុងវិស័យទឹកស្អាតនាពេលបច្ចុប្បន្ននេះ។ លើមូលដ្ឋាននេះ និងដោយការវិវត្តនានានៃស្ថានភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសលេខ ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារF ជាន់ទី២ បន្ទប់លេខ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមដំណាច់ត្រីមាសទី២ ឆ្នាំ២០២៥ សមាគមមានសមាជិកសរុបចំនួន ៣៣៤ស្ថានីយផ្គត់ផ្គង់ទឹកស្អាត/ក្រុមហ៊ុន ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកអាជីពចំនួន ២៨០ស្ថានីយ និងសមាជិកគាំទ្រចំនួន ៥៤ក្រុមហ៊ុន។

## ២.  ការងារសួលសមាគម
### ២.១ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ សមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រីមាសទី១ ដឹកនាំដោយ **លោកស្រី ស៊ីម សៀមនី អនុប្រធានក្រុមប្រឹក្សាភិបាល** នៅការិយាល័យសមាគម និងតាមប្រព័ន្ធអនឡាញ(Zoom Call)។ កិច្ចប្រជុំនេះមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម។

លទ្ធផលនៃអង្គប្រជុំក្រុមប្រឹក្សាភិបាល បានលើកទឹកចិត្តឱ្យសមាគមរៀបចំដូចខាងក្រោម៖

១. រៀបចំ និងផ្សព្វផ្សាយលើបណ្តាញសង្គមរបស់សមាគម អំពីអត្ថប្រយោជន៍នៃការចូលជាសមាជិករបស់សមាគម ដើម្បីឱ្យសមាជិកបានយល់អំពីអត្ថប្រយោជន៍នេះ។

២. រៀបចំថតជាសារខ្លីៗ ដោយជ្រើសរើសយកតំណាងក្រុមប្រឹក្សាភិបាល ២-៣រូប ដើម្បីផលិតជាសារចែករំលែកខ្លីៗអំពីសមាគម អត្ថប្រយោជន៍សមាជិកសមាគម ហើយសារទាំងនេះនឹងធ្វើការផ្សព្វផ្សាយលើបណ្តាញសង្គមរបស់សមាគម។

៣. រាល់ព្រឹត្តិការណ៍របស់សមាគមគួរតែរៀបចំឱ្យមានការផ្សព្វផ្សាយជាព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់សមាគមដូចជា ហ្វេសប៊ុក(Facebook) និងតាមទូរទស្សន៍ ឬ YouTube ជាដើម។ល។

ក្រុមប្រឹក្សាភិបាលបានស្នើឱ្យ **លោក លឹម មិញ** នាយកប្រតិបត្តិ រៀបចំបទបង្ហាញដោយផ្តោតលើ៖ ១. អំពីសមាគម ២. ទិដ្ឋភាពទូទៅនៃអាជីវកម្មទឹកស្អាត និង៣. បញ្ហាប្រឈមរបស់អាជីវករផ្គត់ផ្គង់ទឹកស្អាត សម្រាប់ការចូលរួមប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(ឧ.វ.ប.ន.)។



*រូបភាពទី១៖ កិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាល សម្រាប់ត្រីមាសទី១*

### ២.២. វគ្គបណ្តុះបណ្តាល

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«វិធីសាស្ត្រធ្វើជ្យារតេស្ត និងការវិភាគគុណភាពទឹកស្អាត» សម្រាប់សមាជិកចំនួន ១៦នាក់ មកពីស្ថានីយផ្គត់ផ្គង់ទឹកស្អាតជាសមាជិកចំនួន ១៤នាក់មកពី

ក្រុមហ៊ុនចំនួន១នាក់ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតមិនមែនជាសមាជិកចំនួន ១នាក់។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅនៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ វគ្គបណ្តុះបណ្តាលនេះបានមានទាំងទ្រឹស្តី និងការអនុវត្តន៍ផ្ទាល់នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត សោម៉ា ខូប៉ែលកូ វ៉ៃធើរសើបផ្លាយ ឯ.ក។

ក្រោយពីចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាកាមអាចៈ

១. រៀបរាប់បានពីដំណើរការធ្វើជ្យារតេស្ត និងការវិភាគគុណភាពទឹកស្អាត

២. រៀបរាប់បានពី ប៉ារ៉ាម៉ែត្រប្រចាំថ្ងៃ ប៉ារ៉ាម៉ែត្រប្រចាំត្រីមាស និងប៉ារ៉ាម៉ែត្រប្រចាំឆ្នាំ

៣. រៀបរាប់បានពីវិធីសាស្ត្រសម្រាប់ការវិភាគគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រទាំងប្រាំប្រចាំថ្ងៃ។

ជាលទ្ធផល សិក្ខាកាមបានបង្ហាញពីការពេញចិត្តចំពោះការរៀបចំទីកន្លែងវគ្គបណ្តុះបណ្តាល ខ្លឹមសារមេរៀនបទបង្ហាញរបស់គ្រូឧទ្ទេសមានភាពងាយស្រួលយល់ និងបានអនុវត្តជាក់ស្តែងលើការវិភាគគុណភាពទឹកស្អាត និងធ្វើជ្យារតេស្តទឹកឆៅ។

សិក្ខាកាមបានស្នើសុំឱ្យសមាគមបន្តបើកវគ្គបណ្តុះបណ្តាស្តីពី ១). វិធីសាស្ត្រធ្វើជ្យារតេស្ត និងការវិភាគគុណភាពទឹកស្អាត ២). ការគ្រប់គ្រងទឹកបាត់បង់ ៣). ប្រព័ន្ធគណនេយ្យ ៤). ការសិក្សាថ្លៃដើមផលិតទឹក ជូនដល់សមាជិកសមាគម។



*រូបភាពទី២៖ ទស្សនកិច្ចសិក្សាទៅកាន់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សោម៉ា ខូប៉ែលកូ*

## ២.៣. ការសម្របសម្រួលសមាជិក

❖ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥ តំណាងសមាគមបានចូលរួមកិច្ចប្រជុំដោះស្រាយបញ្ហាគុណភាពទឹកស្អាត និងការធ្លាក់ចុះសម្ពាធទឹករបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតភូមិយើង ដែលមានទីតាំងនៅភូមិតាកយ ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ កិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តម ជា វេង អនុរដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន.** និង មន្ត្រីបច្ចេកទេស លោកប្រធានមន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ចាម និងសហការី មន្ទីរព័ត៌មានខេត្ត លោកអភិបាលនៃគណៈអភិបាលស្រុកស្រីសន្ធរ មន្ត្រីបច្ចេកទេសរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្រុមប្រឹក្សាឃុំព្រែកដំបូក ព្រះសង្ឃ ប្រតិបត្តិករទឹកស្អាត តំណាងសមាគមCWA ព្រមទាំងប្រជាពលរដ្ឋប្រមាណ ៣០នាក់។ វិស្វករបច្ចេកទេសរបស់សមាគមបានវិភាគគុណភាពទឹក និងវាស់សម្ពាធទឹកឃើញថា ទាំងគុណភាពទឹក និងសម្ពាធទឹកគឺអនុលោមតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ។ ជាលទ្ធផលក្រោយពេលទទួលបានការរាយការណ៍ពីភាគីពាក់ព័ន្ធមក **ឯកឧត្តម ជា វេង** បានសម្រេចជារួមដូចខាងក្រោម៖

✓ ចំពោះការផ្លាស់ប្តូរម្ចាស់អាជីវកម្មមិនអាចធ្វើបានភ្លាមៗតាមចិត្តបាននោះទេ គឺត្រូវការពេលវេលាមួយសម្រាប់ធ្វើតាមនីតិវិធីរបស់ក្រសួង ឧ.វ.ប.ន.។

✓ ឲ្យមន្ត្រីបច្ចេកទេសរបស់ក្រសួងប្រមូលជាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ រួមទាំងគ្រួសារដែលប្រើប្រាស់។

✓ ទឹកស្អាត ដើម្បីរៀបចំជារបាយការណ៍ ដាក់ជូនគណៈកម្មាធិការក្រសួងក្នុងការដោះស្រាយបញ្ហាជូនប្រជាជន និងដាក់លទ្ធផលជូន **ឯកឧត្តមរដ្ឋមន្ត្រី** ដើម្បីសម្រេច។

✓ ស្នើសុំសមាគមបន្តផ្តល់ការគាំទ្របច្ចេកទេសបន្ថែមដល់ប្រតិបត្តិករ ដើម្បីធ្វើឲ្យប្រសើរឡើងនូវសេវាផ្គត់ផ្គង់ទឹកស្អាត។

✓ ចាត់តាំងក្រុមការងារបច្ចេកទេសក្រសួង រដ្ឋាករទឹក និងមន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ចាម ដើម្បីចុះទៅសួរនាំប្រជាពលរដ្ឋដែលបានប្រើប្រាស់ទឹកស្អាត អំពីបញ្ហា គុណភាពទឹក និងសម្ពាធទឹក ក៏ដូចជាការធ្វើតេស្តគុណភាពទឹក និងវាស់សម្ពាធនៅចុងបណ្តាញផងដែរ។



*រូបភាពទី៣៖ ការចូលរួមកិច្ចប្រជុំដោះស្រាយបញ្ហាគុណភាពទឹក និងសម្ពាធទឹកនៅស្ថានីយទឹកស្អាតភូមិយើង*

❖ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥ សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត រៀបចំកិច្ចពិភាក្សាតាមប្រព័ន្ធអនឡាញ និងផ្សាយផ្ទាល់ជាសាធារណៈនៅលើទំព័រហ្វេសប៊ុករបស់សមាគម លើប្រធានបទចំនួន

ពីរគឺ១). ក្រសួងអនុញ្ញាតឱ្យក្រុមហ៊ុនចិនសិក្សាសមិទ្ធិលទ្ធភាពក្នុងការលក់ទឹកដុំសម្រាប់ខេត្តតាកែវ កណ្តាល និងខេត្តបាត់ដំបង។ ២). ការឆ្លើយតបរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើករណីការស្នើសុំកិច្ចអន្តរាគមន៍ក្នុងការពិចារណាលើលទ្ធភាពគិតបញ្ចូលចំណាយដោះស្រាយផលប៉ះពាល់បណ្តាញផ្គត់ផ្គង់ទឹកស្អាត ទៅក្នុងគម្រោងចំណាយស្ថាបនាជួសជុលហេដ្ឋារចនាសម្ព័ន្ធនានារបស់ក្រសួង-ស្ថាប័ន អង្គភាពដែលមានការពាក់ព័ន្ធជាមួយនឹងបណ្តាញផ្គត់ផ្គង់ទឹកស្អាត» របស់ក្រសួង ឧ.វ.ប.ន.។ កិច្ចពិភាក្សានេះមានអ្នកចូលរួមទាំងសមាជិករបស់សមាគម និងសាធារណៈជនសរុបប្រមាណ ២០០នាក់។




*រូបភាពទី៤៖ កិច្ចពិភាក្សាអនឡាញមួយរវាងសមាគម និងអគ្គនាយកដ្ឋានទឹកស្អាត*

## ២.៤. ការគាំទ្រសមាជិក

ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ មន្ត្រីបច្ចេកទេសទឹកស្អាត របស់សមាគមបានធ្វើការវិភាគគុណភាពទឹកឆៅ ជូនស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ ដើម្បីកំណត់បរិមាណសារធាតុគីមីសម្រាប់យកមកសម្អាតទឹកឱ្យមានគុណភាពស្របតាមស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ។



*រូបភាពទី៥៖ ការវិភាគគុណភាពទឹករបស់ស្ថានីយទឹកស្អាត ចំការលើ*

## ២.៥. កិច្ចប្រជុំថ្នាក់តំបន់ខេត្តសៀមរាប

ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ៨.០០ព្រឹក ដល់ម៉ោង ៥.០០ល្ងាច សមាគមបានសហការជាមួយរដ្ឋបាលខេត្តសៀមរាប រៀបចំកិច្ចប្រជុំថ្នាក់តំបន់ សម្រាប់សមាជិកជាប្រតិបត្តិករអញ្ជើញមកពីខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ កណ្តាល និងសៀមរាប ។ កិច្ចប្រជុំប្រព្រឹត្តទៅក្រោមអធិបតីភាព លោក អ៊ីង គឹមលាង អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តសៀមរាប។

កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ១០០នាក់(ស្រី ១៧នាក់) រួមមាន៖ អភិបាលរងខេត្ត ថ្នាក់ដឹកនាំ និង មន្ត្រីមន្ទីរឧ.វ.ប.ន. ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ មន្ទីរធនធានទឹក និងឧតុនិយម ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តសៀមរាប និងខេត្តកំពង់ធំ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប មន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប លោក/លោកស្រី ថ្នាក់ដឹកនាំ និងសមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម និង អ្នកគាំទ្រកម្មវិធីនានា។ ជាលទ្ធផលកិច្ចប្រជុំបានរកឃើញនូវដំណោះស្រាយសម្រាប់បញ្ហាប្រឈមមួយចំនួនដែលប្រតិបត្តិករ ផ្គត់ផ្គង់ទឹកស្អាតឯកជន និងមន្ទីរពាក់ព័ន្ធបានជួបប្រទះក្នុងវិស័យទឹកស្អាត។ ជំហានបន្ទាប់សមាគមនឹងរៀបចំរបាយការណ៍លម្អិតផ្ញើជូនភាគីពាក់ព័ន្ធដើម្បីផ្តល់ធាតុចូល និងរក្សាទុកក្នុងការអនុវត្តការងារក្នុងវិស័យទឹកស្អាត។



*រូបភាពទី៦៖ កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាប*

### ២.៦. ការកៀរគរប្រភពទុន

- **សំណើសុំថវិកាពីកម្មវិធី CAPRED៖** សមាគមបានសហការជាមួយអង្គការខាងលិចជួបខាងកើត (EMW) ដើម្បីសរសេរសំណើសុំថវិកាទៅកម្មវិធី CAPRED នាដើមខែឧសភា ឆ្នាំ២០២៥។ គម្រោងនោះមានឈ្មោះថា យុទ្ធនាការផ្លាស់ប្តូរឥរិយាបទ និងសង្គមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត ។ សមាគមនិងអង្គការ EMWកំពុងរង់ចាំការឆ្លើយតបពីកម្មវិធីCAPRED។
- **សំណើសុំថវិកាពីមូលនិធិអភិវឌ្ឍន៍ជំនាញ៖**សមាគមបានជួបពិភាក្សាការងារជាមួយក្រុមហ៊ុន iSEA ដើម្បីពិភាក្សាអំពីកិច្ចសហការក្នុងការរៀបចំសំណើសុំថវិការួមគ្នាដើម្បីដាក់ទៅមូលនិធិអភិវឌ្ឍន៍ជំនាញ។ ជាលទ្ធផលអង្គភាពទាំងពីរបានសម្រេចសរសេរពាក្យស្នើសុំថវិកាដោយផ្តោតទៅលើការកសាងសមត្ថភាពរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត លើការវិភាគគុណភាពទឹក។

## ៣. កិច្ចសហប្រតិបត្តិការ

### ៣.១ កិច្ចសហការអន្តរជាតិ

#### ៣.១.១. សន្និសីទ និងពិព័រណ៍ទឹក( OZWATER’2025) នៅទីក្រុង Adelaide ប្រទេសអូស្ត្រាលី

ថ្ងៃទី២០-២២ ខែឧសភា ឆ្នាំ២០២៥ AWA បានរៀបចំសន្និសីទ និងពិព័រណ៍ទឹក នៅទីក្រុង Adelaide សម្រាប់ប្រមូលផ្តុំអ្នកជំនាញគោលនយោបាយ អ្នកបច្ចេកទេស នៅជុំវិញវិស័យទឹក ដើម្បីពិភាក្សា បង្កើនកិច្ចសហការ ចែករំលែកចំណេះដឹង និងស្វែងរកដំណោះស្រាយ ប្រកបដោយភាពច្នៃប្រឌិតចំពោះបញ្ហាទឹកនាសម័យរួមទាំងការតាំងពិព័រណ៍ទឹកប្រចាំឆ្នាំដ៏សំខាន់មួយរបស់សមាគមទឹកអូស្ត្រាលី។

សន្និសីទមានគោលបំណងប្រមូលផ្តុំអ្នកជំនាញទឹកដើម្បីដោះស្រាយបញ្ហាសំខាន់ៗដូចជាការប្រែប្រួលអាកាសធាតុ សន្តិសុខទឹក ការផ្លាស់ប្តូរបែបឌីជីថល និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ប្រធានបទ «មើលទៅក្រោយ ឆ្ពោះទៅមុខ» (Looking Back, Moving forward) ដោយផ្តោតលើការប្រើប្រាស់បទពិសោធន៍អតីតកាល ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងបង្កើតរបកគំហើញនាពេលអនាគតក្នុងការគ្រប់គ្រង ធនធានទឹក និងការអភិវឌ្ឍន៍ផ្នែកឌីជីថល ក្នុងឧស្សាហកម្មទឹក។ ប្រតិភូរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ចំនួន ៦រូប បានចូលរួមក្នុងសន្និសីទនេះដែរ និងបានចូលរួម ១).កិច្ចស្វាគមន៍របស់ក្រុមប្រឹក្សាភិបាលសមាគមទឹកអូស្ត្រាលី ២). អាហារប្រធានសមាគមទឹកអូស្ត្រាលីពេលរាត្រី(President’s Dinner) ៣). ធ្វើបទបង្ហាញ «ឱកាសនៃការវិយោគលើវិស័យទឹកស្អាតនៅកម្ពុជា» ក្នុងនោះក៏មានបទបង្ហាញ ពីសមាគមបីផ្សេងទៀតដែរ VWSA, PERPAMSI, Pacific Water and Westwater Association. ៤).ជាវាគ្មិនក្នុងការពិភាក្សាពីបញ្ហាប្រឈម និងដំណោះស្រាយ លើការផ្គត់ផ្គង់ទឹកស្អាតក្នុងបរិបទបម្រែបម្រួលអាកាសធាតុ ៥). Afternoon Tea Networking និង៦). Australian Water Awards ដែលជាពិធីជប់លៀងអាហារពេលល្ងាច (Gala Dinner) អបអរសាទរសមិទ្ធិផលឆ្នើម និងការច្នៃប្រឌិតក្នុងវិស័យទឹក គោលបំណងជំរុញកិច្ចសហការ បំផុសគំនិត ច្នៃប្រឌិត និងជំរុញវឌ្ឍនភាពឆ្ពោះទៅ រកអនាគតទឹក ប្រកប ដោយនិរន្តរភាព និងភាពធន់នៃបម្រែបម្រួលអាកាសធាតុជាសាកល។ នាយកប្រតិបត្តិ និងគណៈប្រតិភូកម្ពុជា បានចូលរួមក្នុងកម្មវិធីនេះ។ សន្និសីទនេះមានប្រតិភូកម្ពុជា មកពីក្រសួង ឧ.វ.ប.ន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងកិច្ចការនារី និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។





*រូបភាពទី៧៖ សន្និសីទ និងពិព័រណ៍ទឹក នៅទីក្រុង Adelaide*

### ៣.១.២. សន្និសីទ និងពិព័រណ៍ទឹកប្រទេសឥណ្ឌូនេស៊ី( IWWEF)

លោក លឹម មិញ នាយកប្រតិបត្តិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួមសន្និសីទទឹក និងពិព័រណ៍ឥណ្ឌូនេស៊ី ថ្ងៃទី១១-១៣ ខែមិថុនា ឆ្នាំ២០២៥ នៅទីក្រុង Jakarta ប្រទេសឥណ្ឌូនេស៊ី។ ក្នុងនោះ ក៏បានចូលរួមប្រជុំសមាគមទឹកនៅអាស៊ីអាគ្នេយ៍ Southeast Asian Water Utilities Network (SEAWUN ) និងបានចែករំលែកពី «ការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា និងតួនាទីសមាគមក្នុងការចូលរួមលើវិស័យទឹកស្អាត»។




*រូបភាពទី៨៖ សន្និសីទ និងពិព័រណ៍ទឹកប្រទេសឥណ្ឌូនេស៊ី*

### ៣.១.៣. សន្និសីទ និងពិព័រណ៍ទឹកប្រទេសសិង្ហបុរី

ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥ លោក លឹម មិញ នាយកប្រតិបត្តិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួម Singapore International Water Week – Spotlight 2025 នៅប្រទេសសឹង្ហបុរី។ ក្នុងនោះបានចូលរួមជាវាគ្មិនកិត្តិយសក្នុងការចែករំលែកអំពី បញ្ហាប្រឈម និងឱកាសក្នុងការវិនិយោគលើវិស័យទឹកស្អាតនៅកម្ពុជា។ ជាងនេះទៅទៀត សមាគម(CWA) បានចុះអនុស្សរណៈយោគយល់គ្នា (MoU) ជាមួយសមាគមទឹកសិង្ហបុរី (SWA) ដែលជាជំហានដ៏មានអត្ថន័យឆ្ពោះទៅរកការជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់ក្នុងវិស័យទឹក។







*រូបភាពទី៩៖ សន្និសីទ និងពិព័រណ៍ទឹក នៅប្រទេសសិង្ហបុរី*

### ៣.១.៣. កិច្ចប្រជុំជាមួយក្រុមហ៊ុន GEOCRAFT

ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ សមាគមបានទទួលជួបប្រជុំ ជាមួយក្រុមហ៊ុន GEOCRAFT ដើម្បីពិភាក្សាអំពីឱកាសក្នុងការសហការគ្នាដើម្បីដំណើរការប្រព័ន្ធផែនទី (Mapping System) សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅទូទាំងប្រទេសកម្ពុជា។ ក្រោយពីកិច្ចពិភាក្សាដ៏មានផលផ្លែនេះ ក្រុមហ៊ុន GEOCRAFT បានបង្ហាញការចាប់អារម្មណ៍ចូលជាសមាជិកគាំទ្ររបស់សមាគម។

ក្រុមហ៊ុន GEOCRAFT មានបំណងជួយគាំទ្រដល់ការរៀបចំព្រឹត្តិការណ៍សំខាន់ៗរបស់សមាគម រួមមានៈ កិច្ចប្រជុំថ្នាក់តំបន់ ការតាំងពិព័រណ៍ CAMWATER សន្និបាតប្រចាំឆ្នាំ និងសន្និសីទ និងពិព័រណ៍ទឹកស្អាតផងដែរ។



*រូបភាពទី១០៖ កិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុន GEOCRAFT*

## ៣.២ កិច្ចសហការថ្នាក់ជាតិ

### ៣.២.១. កិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥ សមាគមបានចូលរួមកិច្ចប្រជុំ ដែលរៀបចំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧ.វ.ប.ន. និងសហការី។ ក្នុងនោះដែរសមាគម និងអគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត បានស្នើសុំកិច្ចគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់ភាពអនុគ្រោះពន្ធចំនួន ៣ប្រភេទដែលពាក់ព័ន្ធនឹងបន្ទុករបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនៈ

១. ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ និងពន្ធលើប្រាក់ចំណេញ

២. ចាត់ជាបន្ទុករបស់រដ្ឋលើពន្ធអាករបន្ថែម (VAT) លើថ្លៃភ្ជាប់បណ្តាញអតិថិជន ថ្លៃថែទាំនាឡិកា និងសម្ភារៈសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ព្រមទាំងសារធាតុគីមីដែលត្រូវបានប្រើប្រាស់នានា

៣. ពន្ធកាត់ទុកលើថ្លៃសេវានានាពាក់ព័ន្ធការដឹកជញ្ជូន និងដាក់បណ្តាញទឹកស្អាត។



*រូបភាពទី១១៖ កិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ៣.២.២. កិច្ចប្រជុំជាមួយក្រសួងពាណិជ្ជកម្ម

ថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ តំណាងសមាគមបានចូលរួមក្នុងពិធីពិសាអាហារការងារពេលព្រឹកលើកទី៣ នៅទីស្ដីការក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** ជាមួយសមាគមពាណិជ្ជកម្មនៅកម្ពុជា ដែលមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី សមាជិកសមាជិកានៃសមាគមពាណិជ្ជកម្មនៅកម្ពុជា ព្រមទាំងមន្ត្រីជំនាញក្រសួងពាណិជ្ជកម្មជាច្រើនរូប។

ពិធីពិសារអាហារការងារពេលព្រឹកនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីទទួលស្ដាប់ និងដោះស្រាយបញ្ហាប្រឈមរបស់វិស័យឯកជន ព្រមទាំងសំណូមពរផ្សេងៗដើម្បីដាក់ចេញនូវវិធានការ ឆ្លើយតបឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការចូលរួមចំណែកអភិវឌ្ឍបរិយាកាសធុរៈកិច្ចពាណិជ្ជកម្មនៅកម្ពុជា ឱ្យកាន់តែមានភាពប្រសើរឡើង។




*រូបភាពទី១២៖ កិច្ចប្រជុំជាមួយក្រសួងពាណិជ្ជកិច្ច*

## ៣.២.៣. ការជួបសម្ដែងការគួរសមជាមួយសាលាខេត្តសៀមរាប

ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥ សមាគមបានចូលសម្ដែងការគួរសម និងពិភាក្សាការងារលើការផ្គត់ផ្គង់ទឹកស្អាត ជាមួយ **លោក ចឹក គឹមជន** នាយករងរដ្ឋបាលខេត្តសៀមរាប និងតំណាងមន្ទីរទទួលបន្ទុកទឹកស្អាត និង អនាម័យ។ **លោក ចឹក គឹមជន** បានលើកឡើងថា សាលាខេត្តគាំទ្រ និងសហការជានិច្ចជាមួយសមាគមសំដៅធ្វើយ៉ាងណាជួយឱ្យប្រតិបត្តិករមានទឹកស្អាតផ្គត់ផ្គង់ជូនប្រជាជនពលរដ្ឋប្រើប្រាស់ឱ្យបានគ្រប់គ្រាន់។



*រូបភាពទី១៣៖ ការចូលជួបសម្ដែងការគួរសម ជាមួយរដ្ឋបាលខេត្តសៀមរាប*

## ៤. ការងារគម្រោង

### ៤.១ គម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមបំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org

### ៤.១.១. ការកសាងសមត្ថភាពផ្នែកហិរញ្ញវត្ថុ

#### ក. វគ្គបណ្តុះបណ្តាល

ថ្ងៃទី៧-៩ ខែឧសភា ឆ្នាំ២០២៥ សមាគមបានសហការជាមួយក្រុមហ៊ុន BanhJi FinTech Co., Ltd. រៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**គណនេយ្យ និងការរាយការណ៍ហិរញ្ញវត្ថុសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត**» នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងបង្កើនចំណេះដឹង និងពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ដោយអនុវត្តកម្មវិធីគណនេយ្យបញ្ជីស្របតាមគោលការណ៍ និងនីតិវិធីគណនេយ្យសម្រាប់អាជីវកម្មទឹកស្អាត។

ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល អ្នកចូលរួមនឹងមានសមត្ថភាព៖

- ស្វែងយល់ពីគោលការណ៍ និងនីតិវិធីគណនេយ្យសំខាន់ៗក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលមានគុណភាពខ្ពស់ដោយផ្អែកលើ CIFRS សម្រាប់អាជីវកម្មធុនតូច និងមធ្យម
- អនុវត្តប្រព័ន្ធគណនេយ្យបញ្ជី ស្របតាមគោលការណ៍ និងនីតិវិធីគណនេយ្យសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- វិភាគរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

ជាលទ្ធផល អ្នកចូលរួមមានការកើនចំណេះដឹងស្តីអំពីប្រធានបទដែលបានបង្រៀនពី៤២% មិនយល់ដឹងនៅក្នុងការធ្វើតេស្តមុនវគ្គ ទៅ៤៨%នៅក្នុងការធ្វើតេស្តក្រោយវគ្គ។ សមាសភាពអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះសរុបមានចំនួន ៣៧នាក់(ស្ត្រី ២១នាក់) ដែលអញ្ជើញមកពី អគ្គនាយកដ្ឋាន ទឹកស្អាត នៃក្រសួងឧ.វ.ប.ន. អង្គការWater.org ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកក្រុមហ៊ុន BanhJi FinTech Co., Ltd និងបុគ្គលិកសមាគម។



*រូបភាពទី១៤៖ វគ្គបណ្តុះបណ្តាលស្តីពីគណនេយ្យ និងការរាយការណ៍ហិរញ្ញវត្ថុសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត*

## ខ. ការគាំទ្រប្រតិបត្តិករលើផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

- ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ក្រុមការងារបានសម្របសម្រួលប្រតិបត្តិករចំនួន ១០ស្ថានីយ ដែលស្ម័គ្រចិត្តចូលរួមបដិភាគក្នុងការប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ជី។ កិច្ចពិភាក្សាលើរបៀបវារៈរួមមាន៖ ១. បង្ហាញពីទិដ្ឋភាពទូទៅនៃកិច្ចព្រមព្រៀង ២. ក្រុមការងាររបស់ Banhji ៣. លំហូរការងារ ៤. វិធីសាស្ត្រត្រួតពិនិត្យ។
- ក្រុមការងារសមាគមបានបន្តធ្វើការជាមួយក្រុមហ៊ុនបញ្ជី ដើម្បីចូលរួមគាំទ្រ និងតាមដានអំពីភាពរីកចម្រើននៃការប្រើប្រាស់ប្រព័ន្ធគណនេយ្យបញ្ជី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតបានចំនួន១០ស្ថានីយ។
- ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ ក្រុមការងារសមាគម និងអង្គការ Water.org បានចុះសួរសុខទុក្ខ និងសិក្សាស្វែងយល់អំពីការគ្រប់គ្រងការងារគណនេយ្យ ហិរញ្ញវត្ថុ និងរកវិធីគាំទ្រជូនដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បាភ្នំ ស្ថិតនៅឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ជាលទ្ធផល ក្រុមការងារបានយល់អំពីដំណើរការគ្រប់គ្រងការងារគណនេយ្យ ហិរញ្ញវត្ថុ និងបានផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីធ្វើឱ្យការគ្រប់គ្រងនេះកាន់តែមានភាពប្រសើរឡើង។



*រូបភាពទី១៥៖ ការសួរសុខទុក្ខ និងសិក្សាស្វែងយល់អំពីការគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុ*

## ៤.១.២. ការកសាងសមត្ថភាពផ្នែកបច្ចេកទេស

### ក. ការចុះបង្វឹក

តាមរយៈការគាំទ្ររបស់អង្គការWater.org និងកិច្ចសហការជាមួយ អគ្គនាយកដ្ឋានទឹកស្អាត សមាគមបានផ្តល់ការបង្វឹកលើបច្ចេកទេសវិភាគគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ និងបានសិក្សាពីប្រភពទឹករហូតដល់ស្ថានីយ ជូនដល់អ្នកគ្រប់គ្រង និងបុគ្គលិកស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្នុងគម្រោងចំនួន ១០ស្ថានីយ។



*រូបភាពទី១៦៖ ការចុះបង្វឹកបុគ្គលិកស្ថានីយផ្គត់ផ្គង់ទឹកស្អាត បឹងខ្នារ វង្ស ធារី*

**តារាងឈ្មោះស្ថានីយដែលបានចុះបង្វឹក៖**

| ល.រ | ឈ្មោះស្ថានីយ | ទីតាំង | កាលបរិច្ឆេទ |
|---|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត វង្សធារីបឹងខ្នារ | ខេត្តពោធិ៍សាត់ | ២៧ ឧសភា ២០២៥ |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ថ្មគោល | ខេត្តបាត់ដំបង | ២៨ ឧសភា ២០២៥ |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត តាគត់ | ខេត្តបាត់ដំបង | |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឆាង សោភា | ខេត្តបាត់ដំបង | ២៩ ឧសភា ២០២៥ |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភ្នំក្រវាញ | ខេត្តពោធិ៍សាត់ | ៣០ ឧសភា ២០២៥ |
| ៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ជីក្រែង | ខេត្តសៀមរាប | ០៣ មិថុនា ២០២៥ |
| ៧ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រីស្នំ | ខេត្តសៀមរាប | ០៤ មិថុនា ២០២៥ |
| ៨ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រៃជ្រូក | ខេត្តសៀមរាប | |
| ៩ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រកាពប្រាំ | ខេត្តត្បូងឃ្មុំ | ១៦ មិថុនា ២០២៥ |
| ១០ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កោះមិត្ត | ខេត្តកំពង់ចាម | ១៧ មិថុនា ២០២៥ |





*រូបភាពទី១១៧៖ ការចុះបង្វឹកបុគ្គលិកស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រូគិរី*

## ខ. ការផ្តល់ការគាំទ្រលើការពិនិត្យលទ្ធផលវិភាគគុណភាពទឹកស្អាតលើ ៥ប៉ារ៉ាម៉ែត្រ

សមាគមបានប្រមូលលទ្ធផលវិភាគគុណភាពទឹកស្អាតប្រចាំខែពីសមាជិកគម្រោងចំនួន ៤៨ស្ថានីយ។ ជាលទ្ធផលសមាជិកចំនួន ៣៧ស្ថានីយបានផ្ញើលទ្ធផលវិភាគគុណភាពទឹកស្អាតប្រចាំខែមកសមាគម ក្នុងនោះ ៩ស្ថានីយទទួលបានអនុសាសន៍បន្ថែមពីក្រុមការងារបច្ចេកទេសដើម្បីធ្វើឱ្យប្រសើរឡើងនូវការវិភាគគុណភាពទឹក។

## គ. ការផ្តល់ការគាំទ្រលើការសិក្សាផ្នែកបច្ចេកទេស

សមាគមបានជូនដំណឹងដល់សមាជិកក្នុងគម្រោងដែលគាំទ្រដោយអង្គការ Water.org ទាំងអស់ដែលមានបំណងចង់៖

- គូសផែនទីបណ្តាញបំពង់ផ្គត់ផ្គង់ទឹកស្អាតនៅក្នុងតំបន់សេវាកម្ម
- សិក្សាផ្នែកបច្ចេកទេស (បរិមាណតម្រូវការទឹក បរិមាណ និងគុណភាពប្រភពទឹក សមត្ថភាព រោងចក្រផលិតទឹកស្អាត ការពង្រីកបណ្តាញបំពង់ទឹកស្អាត និងការវិនិយោគ)
- គម្រោងនឹងផ្តល់ការ**ឧបត្ថម្ភលើថ្លៃគូសបណ្តាញបំពង់ទឹកស្អាត ឬ សិក្សាផ្នែកបច្ចេកទេស ចំនួន ៥០% ហើយប្រតិបត្តិករចូលរួមបដិភាគចំនួន ៥០%**។

ជាលទ្ធផលមានប្រតិបត្តិករចំនួន១ស្ថានីយបានដាក់ពាក្យស្នើសុំមកសមាគមដើម្បីសិក្សាលើផ្នែកបច្ចេកទេស និងផែនការអាជីវកម្ម។

### ៤.១.៣. ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

## ក. ការសម្របសម្រួលកម្ចី

គម្រោងបានសម្របសម្រួល និងតាមដានសមាជិកដែលទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ(FIs)។ ជាលទ្ធផលប្រតិបត្តិករចំនួន ៤ស្ថានីយបានទទួលប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្មចំនួន៧៦៥.០០០ដុល្លារអាមេរិក ពីធនាគារ SME Bank ធនាគារអេស៊ីលីដា និងធនាគារ FTB។ ទន្ទឹមនឹងនេះ ស្ថានីយចំនួន ៣ទៀតកំពុងសិក្សាកម្ចីពីធនាគារ SME Bank និងធនាគារ FTB។

ក្រៅពីនេះសមាគមក៏បានណែនាំប្រតិបត្តិករដែលមានតម្រូវការកម្ចីឱ្យទំនាក់ទំនងទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុដែលជាដៃគូរបស់សមាគម និងអង្គការ Water.org ផងដែរ។

## ខ. កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា

១. កិច្ចប្រជុំស្តីពីការធានាប្រាក់កម្ចី និង MoU៖ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ CWA, Water.org និង CGCC បានបើកកិច្ចប្រជុំមួយដើម្បីពិភាក្សាអំពីកិច្ចសហការនាពេលអនាគតក្នុងចំណោមភាគីទាំងបី ដើម្បីគាំទ្រការធានាប្រាក់កម្ចីសម្រាប់ប្រតិបត្តិករទឹកឯកជន (PWOs)។

២. កិច្ចប្រជុំស្តីពីលក្ខខណ្ឌប្រាក់កម្ចី និងកិច្ចសហការនាពេលអនាគត៖ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២៥ ក្រុមការងារគម្រោងបានជួបប្រជុំជាមួយធនាគារ ជីប ម៉ុង ដើម្បីណែនាំអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងស្វែងយល់ពីការអភិវឌ្ឍន៍ផលិតផលកម្ចីដែលតម្រូវសម្រាប់ប្រតិបត្តិករទឹកឯកជន (PWOs)។ CWA បានផ្តល់អនុសាសន៍ថាធនាគារគួរផ្តល់ជូននូវជម្រើសហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការរបស់ PWOs។ ធនាគារ ជីប ម៉ុង យល់ព្រមចែករំលែកការអភិវឌ្ឍផលិតផលកម្ចីជាមួយ CWA ដើម្បីពិនិត្យ និងផ្តល់យោបល់។

៣. កិច្ចប្រជុំស្ដីពីកិច្ចសហប្រតិបត្តិការនាពេលអនាគត (MoU)៖ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៥ ក្រុមគម្រោងបានជួបប្រជុំជាមួយ FTB និង GRET ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការនាពេលអនាគតដែលមានសក្ដានុពល។ ជាលទ្ធផលនៃកិច្ចប្រជុំ FTB បានយល់ព្រមបង្កើតអនុស្សរណៈយោគយល់គ្នា (MoU) ជាមួយ CWA ដើម្បីគាំទ្រដល់សមាជិក PWOs របស់ខ្លួន។ GRET បានបង្ហាញចំណាប់អារម្មណ៍ក្នុងការស្វែងរកតំបន់សក្ដានុពលសម្រាប់កិច្ចសហការនាពេលអនាគត។

៤. កិច្ចប្រជុំស្ដីពីការបញ្ចប់ MoU៖ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥ CWA និង CGCC បានបើកកិច្ចប្រជុំមួយដើម្បីបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងភាគីទាំងពីរ។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំ CGCC បានយល់ព្រមផ្ដល់អត្រាការប្រាក់ ០.៧៥% សម្រាប់ប្រតិបត្តិករទឹកឯកជន (PWOs)។

## គ. កសាងសមត្ថភាព និងចំណេះដឹងលើវិស័យហិរញ្ញប្បទាន

❖ សមាគមបានសម្របសម្រួលអញ្ជើញសមាជិកចូលរួមកម្មវិធីកសាងសមត្ថភាពសហគ្រិនរបស់សាជីវកម្មឥណទានកម្ពុជាវគ្គទី៤ ក្រោមប្រធាន«**ការរៀបចំផែនការអាជីវកម្មសម្រាប់កម្ចីអាជីវកម្មខ្នាតតូច និងមធ្យម**» នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ នៅខេត្តកំពង់ចាម។ ជាលទ្ធផលប្រតិបត្តិករចំនួន ១៩នាក់មកពី១៩ស្ថានីយ បានចូលរួមក្នុងកម្មវិធី។

❖ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥ សមាគមបានសហការជាមួយក្រសួងឧ.វ.ប.ន. តាមរយៈ អគ្គនាយកដ្ឋានទឹកស្អាត បានបើកវគ្គបណ្ដុះបណ្ដាលមួយ ស្ដីអំពី អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជននៅប្រទេសកម្ពុជា នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ។ សមាសភាពអ្នកចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនេះសរុបមានចំនួន ៣៥នាក់(ស្រី៥នាក់) ដែលអញ្ជើញពី អគ្គនាយកដ្ឋានទឹកស្អាត ថ្នាក់ដឹកនាំ និងបុគ្គលិកធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (SME Bank) និងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។

ក្រោយបញ្ចប់វគ្គបណ្ដុះបណ្ដាល អ្នកចូលរួមនឹងមានលទ្ធភាព៖

- ពិពណ៌នាអំពីទិដ្ឋភាពទូទៅនៃវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា
- កំណត់អត្តសញ្ញាណរួមនៃដំណើរការអាជីវកម្មទឹកស្អាតឯកជន(ភាពខ្លាំង បញ្ហាប្រឈម និងឱកាសរបស់ប្រតិបត្តិករ)
- កំណត់ការវិនិយោគសំខាន់ៗក្នុងអាជីវកម្មទឹកស្អាត(ប្រភពទឹក រោងចក្រផលិតទឹកស្អាត ការចែកចាយ ប្រតិបត្តិការ (អគ្គិសនី ម៉ូទ័រ បុគ្គលិក សារធាតុគីមី)
- កំណត់ហានិភ័យ និងឱកាសក្នុងការវិនិយោគក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត។

យោងតាមលទ្ធផលសង្ខេបនៃការធ្វើតេស្តមុន និងក្រោយវគ្គ បានបង្ហាញថា សិក្ខាកាមបានកើនចំណេះដឹងរបស់ពួកគេលើប្រធានបទដែលបានបង្រៀននៅក្នុងវគ្គបណ្ដុះបណ្ដាល។ ចំណេះដឹងរបស់សិក្ខាកាមបានកើនឡើងពីពិន្ទុមធ្យមសរុប ៨៩% មុនវគ្គបណ្ដុះបណ្ដាលដល់ ៩៧% (កើនឡើង ៨%) នៅក្រោយវគ្គបណ្ដុះបណ្ដាល។



*រូបភាពទី១៨៖ វគ្គបណ្ដុះបណ្ដាលអំពីអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជន*

## ឃ. ការបង្កើនកិច្ចសហការជាដៃគូ

- ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ សមាគមបានជួបជាមួយសាជីវកម្មធានាឥណទានកម្ពុជា(CGCC) ដើម្បីពិនិត្យមើលលទ្ធភាពដែលអង្គភាពទាំងពីរអាចចុះអនុស្សរណៈនៃយោគយល់គ្នាក្នុងគោលបំណងធ្វើយ៉ាងណាបម្រើផលប្រយោជន៍ដល់សមាជិករបស់សមាគម។

## ៤.១.៤. ពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពប្រតិបត្តិការរបស់សមាជិកជាប្រតិបត្តិករ

១. ក្រោមការឧបត្ថម្ភពីអង្គការ Water.org សមាគម ស្នើសុំកិច្ចសហការជាមួយក្រសួង ឧ.វ.ប.ន. ក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រសួង និងភាគីពាក់ព័ន្ធស្ដីពី«ធ្វើការរួមគ្នាដើម្បីបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»។ កិច្ចប្រជុំរៀបនេះចំឡើងនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ ដោយមានការអញ្ជើញចូលរួមមកពី ក្រសួង អង្គភាព និងដៃគូពាក់ព័ន្ធ រួមមាន៖ ១).ក្រសួងឧ.វ.ប.ន. ២).ក្រសួងសាធារណការ និងដឹកជញ្ជូន ៣).ក្រសួងធនធានទឹក និងឧតុនិយម ៤).ក្រសួងអភិវឌ្ឍន៍ជនបទ ៥).ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៦).ក្រសួងរ៉ែ និងថាមពល ៧).ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៨).ក្រសួងមហាផ្ទៃ ៩).នាយកដ្ឋានវិស្វកម្មនៃក្រសួងការពារជាតិ ១០).ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និង ១១).ដៃគូអភិវឌ្ឍន៍ក្នុងវិស័យទឹកស្អាត រួមមាន៖ អង្គការ Water.org, AFD, CAPRED, JICA និងក្រុមការងារសមាគម សរុបចំនួន ៦០នាក់ (ស្រី ១៥នាក់)។



*រូបភាពទី១៩៖ កិច្ចប្រជុំពិគ្រោះយោបល់រវាងក្រសួង និងភាគីពាក់ព័ន្ធ*

### ៤.១.៥. កិច្ចប្រជុំក្នុងគម្រោង

នៅក្នុងត្រីមាសទី២ ក្រុមការងាររបស់គម្រោងបានរៀបចំកិច្ចប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ ក្រុមការងារគម្រោងរបស់សមាគមបានជួបប្រជុំជាមួយអង្គការ Water.org ដើម្បីពិភាក្សាអំពីការផ្ដល់វត្ថុបង្វឹកលើផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុ នៅសណ្ឋាគារ សាន់វេ។

២. ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥ ក្រុមការងារគម្រោងបានជួបប្រជុំជាមួយអង្គការ Water.org ដើម្បីពិភាក្សាការរៀបចំបែបបទដំណើរការស្តង់ដា(Standard Operating Procedure “SOP”) ការចុះសួរសុខទុក្ខ និងគាំទ្របច្ចេកទេសជូនសមាជិកអាជីព។

៣. ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ក្រុមការងារគម្រោងរបស់សមាគម និងអង្គការWater.org បានជួបប្រជុំដើម្បីពិនិត្យមើលលើវឌ្ឍនភាពការងារប្រចាំត្រីមាសទី២ និងលើកផែនការសម្រាប់ត្រីមាសទី៣ ព្រមទាំងជួបប្រជុំជាមួយ **ឯកឧត្តម តន់ សុខជា អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧ.វ.ប.ន.** ដើម្បីសុំយោបល់ និងអនុសាសន៍ក្នុងការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងបទប្បញ្ញាតទឹកស្អាតផងដែរ។

## ៤.២ គម្រោង«កម្មវិធីកម្មសិក្សាវិស្វករទឹកវ័យក្មេង» គាំទ្រដោយកម្មវិធីCAPRED

សមាគមបានចុះកិច្ចព្រមព្រៀងគម្រោងជាមួយកម្មវិធី CAPRED ដើម្បីអនុវត្តគម្រោងដែលមានឈ្មោះថា «កម្មវិធីកម្មសិក្សាវិស្វករទឹកវ័យក្មេង» ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

- រយៈពេលនៃកិច្ចព្រមព្រៀង៖ ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥
- ក្រុមគោលដៅ៖ និស្សិតចំនួន ៤នាក់ នឹងចុះកម្មសិក្សានៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ២។
- គោលបំណងគម្រោង៖ បង្កើនសមត្ថភាព និងធនធានមនុស្សសម្រាប់វិស័យទឹកស្អាត។
  ជាលទ្ធផលសមាគមបានជ្រើសរើសនិស្សិតស្រីចំនួន៤នាក់ ដើម្បីចុះកម្មសិក្សាជាមួយស្ថានីផ្គត់ផ្គង់ទឹកស្អាតដែលជាសមាជិករបស់សមាគមចំនួន២។